# ពិធីការសំរាប់ទីលានវាយកូនហ្គោល: ឧបសម្ព័ន្ធ F

**ការធ្វើបច្ចុប្បន្នភាពថ្មីៗ:**

- 3/31/21 - គឺតត្រឹមថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០២១, ខោនធីឡូសអានជីឡេស, រួមទាំងក្រុងឡុងប៊ិចផងដែរ គឺដាក់អោយស្ថិតនៅចំណាត់ថ្នាក់ពណ៌លឿង ក្រោមផែនការមេរបស់រដ្ឋ ចំពោះសេដ្ឋកិច្ចដែលមានសុវត្ថិភាពជាង មុន។ ជាលទ្ធផលនៃការផ្លាស់ប្តូរចំណាត់ថ្នាក់នេះ គ្មានការផ្លាស់ប្តូរអ្វីនោះឡើយ។
- 3/10/21
  - អនុញ្ញាតិអោយបង្ហាត់ ឬការបង្វឹកជាក្រុម ដោយមានការដាក់កំរិតដល់ក្រុម មិនអោយមានគ្រូបង្វឹក/អ្នកបង្ហាត់លើសពី ២នាក់ ធ្វើការបង្ហាត់ដល់សិស្សចំនួន ១៤ នាក់នោះឡើយ។
  - អាចនឹងរៀបចំអោយមានការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង មិនអោយលើសពី ៤ នាក់ ក្នុងមួយប្រកួត ប្រសិនបើការលេងបែបនេះនឹងមិនបង្កើនវត្តមាននៃចំនួនមនុស្ស នៅកន្លែងលេងនោះ ក្នុងពេលតែមួយ។ ត្រូវរៀបចំកាលវិភាគទុកជាមុនចំពោះការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង ដើម្បីឱ្យទុកអោយមានចន្លោះពេលឃ្លាតគ្នា ពីហ្គេមនីមួយៗមិនតិចជាង ១០ នាទី។ ត្រូវលើកទឹកចិត្តអោយបង់ប្រាក់ជាមុន និងការចុះឈ្មោះតាមអេឡិចត្រូនិក សម្រាប់ការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង។ មានការលើកទឹកចិត្តជាខ្លាំង អោយប្រើនូវប័ណ្ណពិន្ទុអេឡិចត្រូនិក, ព័ត៌មាន និងសន្លឹកច្បាប់។ បើកន្លែងណាដែលប្រើប័ណ្ណពិន្ទុក្រដាសវិញនោះ,សមាជិកម្នាក់ក្នុងក្រុម គួរតែរក្សាពិន្ទុអោយកីឡាករទាំងអស់ ដើម្បីជៀសវាងការប៉ះពាល់ដែលមិនចាំបាច់រវាងកីឡាករទាំងឡាយ។ ការដាក់បង្ហាញអ្នកលក់នៅនឹងកន្លែង ត្រូវតែគោរពតាមពិធីសារលក់រាយដោយផ្ទាល់ និងត្រូវមានចម្ងាយយ៉ាងតិច ៦ ហ្វីត រវាងការដាក់បង្ហាញនានារបស់អ្នកលក់។
  - ត្រូវហាមឃាត់នូវការប្រកួត ឬព្រឹត្តិការណ៍ដែលមានការចូលរួមច្រើនជាងពីរក្រុម។ អនុញ្ញាតិយ៉ាងច្រើនបំផុត អោយមានការប្រកួតតែម្តងប៉ុណ្ណោះ, ក្នុងមួយក្រុម, ក្នុងមួយថ្ងៃ លើកលែងតែមានការអនុញ្ញាតនៅទីនេះ។ "ក្រុម" ត្រូវបានកំណត់ជាក្រុមកីឡាករដែលបង្កើតជាក្រុមមួយ នៅផ្នែកម្ខាងទៀត នៅក្នុងការប្រកួតកីឡា។ "ក្រុម" មិនរាប់បញ្ចូលនូវក្រុម ឬកំរឹតច្រើន ដែលមកពីលីក ឬក្រុមដែលមានបទពិសោធន៍ខ្លាំង ដូចគ្នាតែមួយ (ឧទាហរណ៍ ក្រុមថ្មីថ្មោង, ក្រុមមិនសូវមានបទពិសោធន៍ប្រកួត និងក្រុមមានបទពិសោធន៍ខ្ពស់នានា និងពីសាលា ឬលីកតែមួយ ត្រូវបានគេចាត់ទុកថា ជាក្រុមផ្សេងគ្នា)។
  - លេងច្រើនបំផុតក្នុងមួយថ្ងៃ តែមួយប្រកួត, ក្នុងមួយក្រុមតែប៉ុណ្ណោះ (ឬសម្រាប់ការប្រកួតឯកត្តជនតែមួយហ្គេមតែប៉ុណ្ណោះ)។
  - អាចបើកសារថ្មីឡើងវិញ នូវការអនុវត្តការវាយតំរង់ និងស៊ុតរន្ធឡូកូនគោល តាមវាលស្មៅ។
- ការផ្លាស់ប្តូរនានា បានរំលេចអោយឃើញជាពណ៌លឿង។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

LONGBEACH HEALTH & HUMAN SERVICES

ពិធីការនេះ នឹងត្រូវបានបំពេញដោយទីលានវាយកូនហ្គោល។ តម្រូវការនានាខាងក្រោម អនុវត្តចំពោះគ្រប់ទីលានវាយកូនហ្គោលទាំងអស់។ បន្ថែមពីលើលក្ខ័ណ្ឌ ដែលបានដាក់លើទីលានវាយកូនហ្គោលទាំងអស់ ដោយមន្ត្រីសុខាភិបាល សំរាប់ប្រតិបត្តិការកំសាន្តសប្បាយនៅខាងក្រៅ, ដែលមាន ឬមើលឃើញនៅលើគេហទំព័រ https://covid19.ca.gov/industry-guidance/ ទីលានវាយ កូនហ្គោល ក៏ត្រូវគោរពតាមលក្ខ័ណ្ឌដែលបានដាក់ចេញ នៅក្នុងពិធីការនានាសំរាប់ទីលានវាយកូនហ្គោលនេះ ផងដែរ។ ពិធីការនេះ ត្រូវតែបានអនុវត្ត និងបានបិទប្រកាស ឬផ្សាយមុនពេលដំណើរការទីលានវាយកូនហ្គោល។

- ប្រតិបត្តិការលក់រាយ ត្រូវតែគោរពតាមពិធីសារនៃការលក់រាយដោយមនុស្សផ្ទាល់ (ឧបសម្ព័ន្ធ B) ។
- ភោជនីយដ្ឋាន, សេវាកម្មម្ហូបអាហារ, និងសម្បទានម្ហូបអាហារ ត្រូវតែគោរពតាមពិធីសារភោជនីយដ្ឋាន (ឧបសម្ព័ន្ធ H) ។
- កីឡាសម្រាប់មនុស្សពេញវ័យ និងយុវវ័យ ត្រូវតែគោរពតាម ពិធីសារកីឡាសំរាប់យុវជន និងមនុស្សពេញវ័យ របស់រដ្ឋ ដែលមាននៅលើគេហទំពរ https://www.cdph.ca.gov/Programs/CID/DCDC/Pages/COVID-19/small-groups-child-youth.aspx.
- ការជួលឧបករណ៍ ត្រូវតែគោរពតាមពិធីសារនៃការជួលឧបករណ៍ខាងក្រៅផ្ទះ (ឧបសម្ព័ន្ធ D)។

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថានឹងពិនិត្យមើលលើគេហទំព័រ ឡុងប៊ិច COVID-19 នៅឯ www.longbeach.gov/covid19 ជាប្រចាំដើម្បីទទួលបានព័ត៌មានថ្មីៗនេះ ចំពោះឯកសារនេះ។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក

(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា

(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង

(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន

(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

ផ្នែកសំខាន់ទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីផ្ទៀងផ្ទាង់ខាងក្រោម ហើយត្រូវតែអនុវត្តតាមតម្រូវការនានា នៃពិធីសារបើកឡើងវិញនៃវាលវាយកូនហ្គោល។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

LONGBEACH
HEALTH & HUMAN SERVICES

# ទីលានវាយកូនហ្គោលទាំងអស់ ត្រូវអនុវត្តនូវរាល់វិធានការណ៍នានាដែលអាចអនុវត្តបាន ដែលមានរាយខាងក្រោម ហើយត្រៀមក្នុងការពន្យល់អំពីមូលហេតុអ្វី បានជាវិធានការណ៍ណាមួយដែលមិនត្រូវបានអនុវត្តនោះ មិនអាចអនុវត្តបាន។

ឈ្មោះទីលានវាយកូនហ្គោល: ____________________

អាស័យដ្ឋានកន្លែង: ____________________

## A. ការកត់ឈ្មោះចូលនូវកីឡាករវាយកូនហ្គោល, ការលេងកូនហ្គោល និងអ្វីៗនៅជុំវិញក្លឹបហៅស៍ - ការដាក់កំរិត

- ☐ ផ្លាកសញ្ញាណែនាំ និងព័ត៌មាន ត្រូវបានបិទផ្សាយនៅគ្រប់ទីកន្លែងទាំងអស់ ទាក់ទងទៅនឹងការគ្រប់គ្រងការឆ្លង, ឃ្លាតឆ្ងាយរាងកាយពីគ្នា និងការប្រើប្រាស់គំរបមុខ។
- ☐ ភ្ញៀវដែលមកដល់គ្រឹះស្ថាន ត្រូវបានក្រើនរំលឹកកអោយពាក់គម្របមុខគ្រប់ពេលវេលាទាំងអស់ (លើកលែងតែពេលកំពុងបរិភោគ ឬផឹក, បើអាចអនុវត្តទៅបាន) ក្នុងអំឡុងពេលស្ថិតនៅក្នុងគ្រឹះស្ថាន ឬនៅតាមទីធ្លានានា នៃគ្រឹះស្ថាន។ នេះត្រូវអនុវត្តចំពោះមនុស្សពេញវ័យទាំងអស់ និងចំពោះកុមារអាយុ ២ ឆ្នាំ និងឡើងទៅ។ មានតែឯកត្តបុគ្គលដែលត្រូវបាន ណែនាំមិនអោយពាក់មុខគម្របមុខ ដោយអ្នកផ្តល់សេវាវេជ្ជសាស្រ្តរបស់ពួកគេតែប៉ុណ្ណោះ ដែលត្រូវបានលើកលែងពីការពាក់គម្របមុខ។ ដើម្បីគាំទ្រដល់សុវត្ថិភាពរបស់និយោជិក និងភ្ញៀវទាំងឡាយដទៃទៀត, គម្របមុខ គួរត្រូវបានផ្តល់ជូនដល់ភ្ញៀវ ដែលមកដល់គ្រឹះស្ថាន ដោយគ្មានគម្របមុខ។
- ☐ ការត្រួតពិនិត្យរោគសញ្ញានានា ត្រូវបានធ្វើឡើងមុនពេលភ្ញៀវ អាចចូលទៅក្នុងកន្លែងឬអាគារ។ ការត្រួតពិនិត្យត្រូវតែ រាប់បញ្ចូលការឆែកឆេរទាក់ទងនឹងការក្អក, ដង្ហើមខ្លី ឬដង្ហក់, ពិបាកដកដង្ហើម និងគ្រុនក្តៅ ឬញាក់។ ការត្រួតពិនិត្យទាំងនេះអាចត្រូវបានធ្វើឡើងដោយផ្ទាល់ ឬតាមរយៈវិធីសាស្រ្តជំនួសនានា ដូចជាការត្រួតពិនិត្យតាមប្រព័ន្ធអ៊ិនធឺរណិត ឬតាមរយៈផ្លាកសញ្ញា ដែលត្រូវបានបិទនៅច្រកចូលទីតាំង ដោយបញ្ជាក់ថាភ្ញៀវដែលមានរោគសញ្ញានានាទាំងនេះ មិនគួរចូលក្នុងបរិវេណនោះទេ។
- ☐ ការបង់ថ្លៃបៃតង (វាលស្មៅពណ៌បៃតង) ត្រូវបានធ្វើឡើងពី ឬតាមបង្អួចដែលបែរមុខទៅរកកន្លែងចាប់ផ្តើម នៅខាងក្រៅដែលមានរួចស្រាប់ ឬពីតុ កត់ឈ្មោះចូលនៅខាងក្នុងកន្លែង។ សញ្ញាសំគាល់ចម្ងាយ ៦ ហ្វីត នៃការឃ្លាតឆ្ងាយរាងកាយ ពីគ្នា ត្រូវបានតំឡើងដើម្បីអោយអតិថិជនទាំងឡាយដឹងអំពីកន្លែងដែលត្រូវរង់ចាំបង់ប្រាក់។
- ☐ ទាមទារអោយមានការកក់ ហើយកីឡាករវាយកូនហ្គោល ត្រូវបានលើកទឹកចិត្តអោយបង់ប្រាក់ជាមុន ដោយប្រើកាត ដេប៊ីត/ក្រេឌីត នៅពេលកក់។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ការទូទាត់នៅឯកន្លែងវាយកូនហ្គោល គឺត្រូវធ្វើឡើយជាអំណោយ, កាតដេបីត ឬកាតក្រេឌីត តែប៉ុណ្ណោះ។
- ការគូសសញ្ញាចំណាំ ឬការកំណត់ព្រំដែននានា ត្រូវបានបង្កើតឡើង ដើម្បីបង្កើតជារបាំងដែលមានចម្ងាយ ៦ ហ្វីត នៅជុំវិញតំបន់ចាប់ផ្តើមវាយកូនហ្គោល ដើម្បីកាត់បន្ថយនូវទំនាក់ទំនងជិតស្និទ្ធ រវាងនិយោជក និងសាធារណៈជន។
- ទឹកលាងដៃសម្លាប់មេរោគ, សាប៊ូ និងទឹក ឬ ថ្នាំ ឬវត្ថុ/ជូតសំឡាប់មេរោគ ដែលមានប្រសិទ្ធិភាព ត្រូវដាក់អោយមាន សំរាប់អោយប្រើ ចំពោះកីឡាករលេងកូនហ្គោលនៅឯ ឬនៅក្បែរច្រកចូលនីមួយៗ ឆ្ពោះទៅកាន់កន្លែងលេង នៅតាមរទេះ ភេសជ្ជៈ និងស្ថានីយ៍/កន្លែងអាហារនានា និងបន្ទប់ទឹកទាំងឡាយ។
- ចន្លោះពេល នៃការចាប់ផ្តើមវេនរបស់អ្នក គឺមិនតិចជាង ១០ នាទី ពីគ្នាឡើយ។
- អ្នកលេងមិនត្រូវបានអនុញ្ញាតិអោយមកដល់ទីធ្លាដែលត្រូវវាយកូនហ្គោលគ្រាប់ដំបូង ឬទីធ្លាចាប់ផ្តើមណាមួយនោះឡើយ រហូតដល់ក្រុមមុន បានចាកចេញពីទីធ្លាចាប់ផ្តើម ទៅបាត់អស់ហើយ។
- ប័ណ្ណពិន្ទុ និងខ្មៅដៃ ត្រូវបានប្រគល់ជូន នៅពេលដែលមានការស្នើសុំតែប៉ុណ្ណោះ ហើយមិនត្រូវដាក់នៅលើខោនធើឡើយ។
- ខោនធើសាធារណៈនិងបង្គួចសេវាកម្មទាំងឡាយ បានត្រូវធ្វើអនាម័យជាប្រចាំ។
- ប្រដាប់ព្យួរក្នុងក្លឹប ត្រូវបានដកចេញ ឬបិទអោយជិត។
- ធុងសំរាម គឺមិនអាចប៉ះបាន។ ត្រូវយកគំរបចេញ ប្រសិនបើមាន។
- រទេះវាយកូនហ្គោល ត្រូវមានតែអ្នកជិះម្នាក់ប៉ុណ្ណោះ, ប៉ុន្តែសមាជិកនៅក្នុងគ្រួសារតែមួយ អាចចែករំលែករទេះវាយកូនហ្គោលនេះបាន។
- កីឡាករវាយកូនហ្គោល មិនត្រូវបានអនុញ្ញាតិអោយប៉ះ, ដក ឬកែកុននូវដងទង់ជាតិ ក្នុងអំឡុងជុំ របស់ពួកគេឡើយ។
- រទេះវាយកូនហ្គោល, រទេះជិះ និងរទេះរុញ ត្រូវបានធ្វើអនាម័យ មុន និងក្រោយ ពេលប្រើប្រាស់ម្តងៗ។
- រាល់បន្ទប់ទឹកទាំងអស់នៅទីលានវាយកូនហ្គោល ត្រូវថែទាំលាងសំអាត និងសំឡាប់មេរោគអោយបានញឹកញាប់។ ទ្វារ ត្រូវបានបើកចំហរ នៅពេលដែលអាចធ្វើបាន ដើម្បីកាត់បន្ថយនូវការប៉ះពាល់ដៃ ឬផ្ទៃទ្វារ។
- ដោយសារគ្មានរនាស់រុញដីខ្សាច់, កីឡាករវាយកូនហ្គោលទាំងអស់ ត្រូវបានណែនាំ, ដូចមានចែងនៅក្នុងច្បាប់ USGA COVID 19 ក្នុងការ "ព្យាយាមអោយអស់ពីសមត្ថភាពរបស់ពួកគេ ដើម្បីធ្វើអោយរលោង ឬរាបស្មើរ នូវតំបន់ដែលមាន ការរំខានដោយបាតជើង ឬក្លឹបវាយកូនហ្គោល បន្ទាប់ពីលេងបាល់ របស់ពួកគេរួច"។
- មេរៀនឯកជនត្រូវបានអនុញ្ញាតិ ដោយប្រើនូវបច្ចេកទេសឃ្លាតឆ្ងាយរាងកាយពីគ្នា អោយបាន ៦ ហ្វីតឬច្រើនជាងនេះ សំរាប់បុគ្គលម្នាក់ៗ ។ ទាំងសិស្ស និងគ្រូ នឹងមានតំរូវការអោយពាក់ម៉ាស់ ឬគម្របមុខ។
- រាល់ព័ត៌មានរបស់អ្នកចូលរួម បានត្រូវចែកចាយ និងប្រមូល ក្នុងកំឡុងពេលចុះឈ្មោះ ដែលត្រូវបានធ្វើតាមអេឡិចត្រូនិក មុនពេល

មកដល់។ លើកទឹកចិត្តឱ្យអ្នកចូលរួមបោះពុម្ពចេញដោយខ្លួនឯង ឬមានគម្រោងប្រើប្រាស់ជាទម្រង់ឌីជីថល។

- អ្នកចូលរួម និងគ្រូបង្វឹក ត្រូវបានតម្រូវឱ្យស្ថិតនៅចម្ងាយយ៉ាងតិច ៦ ហ្វីត ពីមួយទៅមួយ ហើយត្រូវតែចៀសវាងពីការទាក់ទងគ្នាទៅវិញទៅមក ដូចជាការចាប់ដៃ, អោបក្រសោបដងខ្លួន, ហៃហ្វាយ និងជល់កណ្តាប់ដៃ។
- គ្រូបង្វឹក និងអ្នកចូលរួមត្រូវ ពាក់គម្របមុខ សម្រាប់ពេលម៉ោងរៀន ឬថ្នាក់ទាំងមូល។
- អនុញ្ញាតិអោយបង្ហាត់ ឬការបង្វឹកជាក្រុម ដោយមានការដាក់កំរិតដល់ក្រុម មិនអោយមានគ្រូបង្វឹក/អ្នកបង្ហាត់លើសពី ២ នាក់ ធ្វើការបង្ហាត់ដល់សិស្សចំនួន ១៤ នាក់នោះឡើយ នៅក្នុងក្រុមដែលមានស្ថេរភាព។
- គ្រូបង្វឹកមិនត្រូវចែករំលែកឧបករណ៍នានាជាមួយគ្រូបង្វឹក ឬអ្នកចូលរួមផ្សេងទៀត ដោយឧបករណ៍ទាំងអស់ មិនត្រូវបាន ធ្វើអនាម័យឡើយ។
- រាល់ឧបករណ៍ទាំងឡាយ ដែលត្រូវបានផ្តល់ជូនអ្នកចូលរួម ត្រូវបានធ្វើអនាម័យជាមុនសិន។ លើសពីនេះទៀត, ឧបករណ៍វាយកូនហ្គោលបាននិយាយទាំងអស់នោះ នឹងនៅរក្សាតែជាមួយសិស្សរូបនោះ ក្នុងមួយថ្នាក់នោះរហូត ហើយនឹងមិនត្រូវបានចែករំលែកឡើយ។
- អ្នកចូលរួមមិនត្រូវកាន់កន្ត្រកកូនហ្គោលវាយយកចម្ងាយ ឬកាបូបដាក់ឥវ៉ាន់ នៅពេលណាមួយនោះឡើយ។
- គ្រូបង្វឹក នឹងនៅជាមួយក្រុមដែលបានចាត់តាំងរបស់ពួកគេ ពេញមួយវគ្គ។ អ្នកចូលរួម មិនត្រូវបង្វែរ ឬផ្លាស់ទៅរក គ្រូបង្វឹក ផ្សេង ក្នុងកំឡុងវគ្គដែលបានផ្តល់អោយនោះឡើយ។
- វគ្គជាប់ៗគ្នា ត្រូវបានធ្វើឱ្យមានពេលវេលា ឬទុកអោយមានចន្លោះពេល ដើម្បីឱ្យបុគ្គលិកអាចធ្វើការរំងាប់មេរោគលើឧបករណ៍នានា និងកាត់បន្ថយនូវការប្រមូលផ្តុំ និងការធ្វើចរាចរណ៍ឆ្លងកាត់ ឬឆ្លងទៅឆ្លងមក នៃសិស្ស ក្នុងពេលចាប់ផ្តើម និងពេល បញ្ចប់វគ្គ។
- មិនអនុញ្ញាតិអោយមានការប្រមូលផ្តុំគ្នា និងតកន្ទុយឡានជាប់ៗគ្នា នៅកន្លែងចតរថយន្តឡើយ។ តម្រូវអោយកីឡាករ ចាកចេញពីទ្រព្យសម្បត្តិភ្លាមៗ នៅពេលបញ្ចប់ការលេង។

សំរាប់និយោជិក ឬបុគ្គលិកដែលមានវត្តមាន នៅនឹងកន្លែង:

- ក្នុងករណីដែលនិយោជិកទាំងអស់ត្រូវបានគេប្រាប់ មិនឱ្យមកធ្វើការ ប្រសិនបើឈឺ, ឬប្រសិនបើពួកគេត្រូវបានប្រឈម នឹងអ្នកដែលមានជំងឺ COVID-19។ និយោជិកយល់ថា ត្រូវធ្វើតាមការណែនាំរបស់ DPH សំរាប់ការដាក់ខ្លួនឯងអោយនៅឯកោ និងដាក់ខ្លួនអោយដាច់ដោយឡែកពីគេ/ចត្តាឡីស័ក, ប្រសិនបើអាចអនុវត្តបាន។ គោលនយោបាយឈប់សម្រាកនៅកន្លែងធ្វើការ ត្រូវបានពិនិត្យឡើងវិញ និងបានត្រូវកែប្រែ ដើម្បីធានាថានិយោជិកមិនត្រូវបានពិន័យ នៅពេលពួកគេស្នាក់នៅផ្ទះដោយសារជំងឺ។
    - ត្រូវផ្តល់ព័ត៌មានដល់និយោជិកទាំងអស់ អំពីអត្ថប្រយោជន៍ នៃការឈប់សម្រាកដែលបានឧបត្ថម្ភដោយនិយោជក ឬរដ្ឋា ភិបាល ដែលនិយោជិក អាចមានសិទ្ធិទទួលបាន ដែលនឹងធ្វើអោយវាកាន់តែមានភាពងាយស្រួលខាងផ្នែកហិរញ្ញវត្ថុ ក្នុងពេលស្នាក់នៅ

ផ្ទះ។ សូមមើលព័ត៌មានបន្ថែម ស្តីពីកម្មវិធីរបស់រដ្ឋាភិបាល ដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងរបស់កម្មករសម្រាប់ ជំងឺ COVID19, រួមមានសិទ្ធិឈប់សម្រាកឈឺរបស់និយោជិក ក្រោមច្បាប់ឆ្លើយតបជំងឺខូរ៉ូណាវីរុសគ្រួសារជាចំបង និងសិទ្ធិរបស់និយោជិក ចំពោះអត្ថប្រយោជន៍សំណងរបស់កម្មករ និងការសន្មតថា ការងារដែលជាប់ទាក់ទងនឹងជំងឺ COVID-19 ដោយអនុលោមតាមបទបញ្ជាប្រតិបត្តិរបស់អភិបាលរដ្ឋ លេខ N-62-20។

- នៅពេលទទួលបានដំណឹងថានិយោជិកម្នាក់ ឬច្រើននាក់ ធ្វើតេស្ដ៍វិជ្ជមាន, ឬមានរោគសញ្ញាស្របគ្នាទៅនឹងជំងឺ COVID-19 (ករណី), និយោជក ត្រូវមានផែនការ ឬពិធីសារដើម្បីអោយករណីដាក់ខ្លួនគេអោយនៅ ឯកោនៅផ្ទះ ហើយតម្រូវអោយនៅឃ្លាតដាច់ឆ្ងាយពីគេឬធ្វើចត្តាឡីស័កខ្លួនឯងជាបន្ទាន់ ចំពោះ ឬនៃនិយោជិកទាំងអស់ ដែលមានការប្រឈមនៅនឹងកន្លែងធ្វើការ ទៅនឹងករណី (ច្រើន)។ ផែនការរបស់និយោជក គួរតែពិចារណាលើពិធីការសម្រាប់និយោជិកដែលបានធ្វើចត្តាឡីស័កទាំងអស់ ដើម្បីអោយមានលទ្ធភាពធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សំរាប់ជំងឺ COVID-19 ដើម្បីកំណត់ថា តើមានការប្រឈមនៅកន្លែងធ្វើការបន្ថែមទៀតដែរឬទេ, ដែលអាចតម្រូវអោយមានវិធានការណ៍ត្រួតពិនិត្យជំងឺ COVID-19 បន្ថែម។ សូមមើលការ ណែនាំសុខភាពសាធារណៈ ស្តីពី ការឆ្លើយតបទៅនឹងជំងឺ COVID-19 នៅកន្លែងធ្វើការ។

  ការចំរាញ់ ឬត្រួតពិនិត្យនិយោជិក ត្រូវបានធ្វើឡើងមុនពេលដែលបុគ្គលិកអាចចូលកន្លែងធ្វើការ។ ការត្រួតពិនិត្យត្រូវតែ រាប់បញ្ចូលការឆែកឆេរទាក់ទងនឹងការក្អក, ដង្ហើមខ្លី ឬដង្ហក់, ពិបាកដកដង្ហើម និងគ្រុនក្តៅ ឬញាក់ និងប្រសិនបើនិយោជិកមានទំនាក់ទំនងជាមួយមនុស្សដែលត្រូវបានគេស្គាល់ថា បានឆ្លងជំងៃ COVID-19 ក្នុងរយៈពេល ១៤ ថ្ងៃចុងក្រោយ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់ នៅពេលការមកដល់របស់និយោជិក។ ផងដែរ ការត្រួតពិនិត្យ សីតុណ្ហភាព ក៏គួរតែត្រូវបានធ្វើ នៅកន្លែងធ្វើការ ប្រសិនបើអាចធ្វើទៅបាន។

- ក្នុងករណីដែលមានករណីចំនួន ៣ ឬ ច្រើនជាងនេះត្រូវបានរកឃើញ នៅក្នុងកន្លែងធ្វើការ ក្នុងរយៈពេល ១៤ ថ្ងៃ និយោជក គួរតែរាយការណ៍ចង្កោមនេះ ទៅកាន់នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស តាមលេខ ៥៦២-៥៧0-INFO។

- យោជិកនានា ដែលមានទំនាក់ទំនងជាមួយអ្នកដទៃ ត្រូវបានផ្តល់ជូន, ដោយឥតគិតថ្លៃ, នូវគម្របមុខសមរម្យដែលគ្របច្រមុះ និងមាត់។ ការគ្រប គឺត្រូវពាក់ដោយនិយោជិក គ្រប់ពេលវេលាទាំងអស់ ក្នុងកំឡុងពេលថ្ងៃធ្វើការនៅពេលមានទំនាក់ទំនង ឬទំនងជាទាក់ទងជាមួយអ្នកដទៃ។

- និយោជិកនានា ដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្រ្តរបស់ពួកគេ ថាពួកគេមិនគួរពាក់គម្របមុខបាន គួរតែពាក់ខែលការពារមុខ ជាមួយ ឬដោយប្រើក្រវ៉ាត់នៅលើគែមខាងក្រោម, អោយត្រូវនឹងសេចក្តីណែនាំរបស់រដ្ឋ, ដរាបណា លក្ខ័ណ្ឌរបស់ពួកគេអនុញ្ញាតិអោយ។ ក្រវ៉ាត់ ដែលត្រូវបានបង្កើតជាទម្រង់សមក្លឹបល្អម នៅក្រោមចង្កា ត្រូវបានគេពេញចិត្ត។ ម៉ាស់ដែលមានវ៉ាល់មួយផ្លូវ មិនគួរត្រូវបានប្រើឡើយ។

- និយោជិក ត្រូវបានណែនាំអោយបោកសំអាត គម្របមុខរបស់ពួកគេ ជារៀងរាល់ថ្ងៃ។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- និយោជិកទាំងអស់ ត្រូវបានរំលឹកអោយប្រកាន់ខ្ជាប់នូវសកម្មភាពការពារផ្ទាល់ខ្លួននានា ជារួមមានៈ
  - ស្នាក់នៅផ្ទះ នៅពេលដែលអ្នកឈឺ។ ស្នាក់នៅផ្ទះយ៉ាងហោចណាស់ ៣ ថ្ងៃ (៧២ ម៉ោង) បន្ទាប់ពីការជាសះស្បើយ, ដែលមានន័យថា គ្រុនក្តៅរបស់អ្នកបានត្រូវដោះស្រាយ ដោយមិនចាំបាច់ប្រើថ្នាំបន្ថយកំដៅទេ ហើយវាមានភាពប្រសើរឡើង នៃរោគសញ្ញាផ្លូវដង្ហើមនានារបស់អ្នក (ឧទាហរណ៍., ក្អក, ដង្ហើមខ្លី ឬដង្ហក់), និងយ៉ាងហោច ណាស់ ១០ ថ្ងៃបានកន្លងផុតទៅ តាំងតែពីរោគសញ្ញាដំបូងរបស់អ្នក បានបង្ហាញចេញមក។
  - លាងដៃរបស់អ្នកអោយបានញឹកញាប់ ជាមួយសាប៊ូ និងទឹក យ៉ាងហោចណាស់ ២០ វិនាទី។ ប្រសិនបើមិន មានសាប៊ូ និងទឹកទេនោះ, សូមប្រើទឹកលាងដៃអនាម័យដែលមានជាតិអាល់កុល យ៉ាងហោចណាស់ ៦០%។ លាងដៃរបស់អ្នក មុនពេលញុំាអាហារ, បន្ទាប់ពីប្រើបន្ទប់ទឹករួច និងក្រោយពេលក្អក និងកណ្តាស់។
  - ខ្ទប់ក្អក និងកណ្តាស់របស់អ្នក ជាមួយនឹងក្រដាសស្តើង ហើយបន្ទាប់មក បោះក្រដាសស្តើងនោះចោល ហើយសម្អាតដៃរបស់អ្នកភ្លាមៗ។ ប្រសិនបើអ្នកមិនមានក្រដាសស្តើងទេនោះ សូមប្រើកែងដៃរបស់អ្នក (មិនមែនដៃ របស់អ្នកទេ)។
  - កុំប៉ះពាល់មាត់, ភ្នែក, ច្រមុះរបស់អ្នក ដោយដៃដែលមិនទាន់លាងសំអាត។
  - ជៀសវាងការទំនាក់ទំនង ឬប៉ះពាល់ជាមួយមនុស្សឈឺ។
  - ជៀសវាងការចែករំលែករបស់របរប្រើប្រាស់ ដូចជាទូរស័ព្ទ ឬឧបករណ៍ផ្សេងៗទៀត។ ប្រសិនបើឧបករណ៍ត្រូវតែចែករំលែក ត្រូវធ្វើអោយប្រាកដថា ជូតសំអាតវា ដោយប្រើប្រដាប់ជូតសំឡាប់មេរោគ មុន និងក្រោយ ពេលចែក រំលែក។
  - សង្កេតជានិច្ច នូវចម្ងាយការងាររបស់អ្នក នៃទំនាក់ទំនងជាមួយនឹងបុគ្គលិកផ្សេងទៀត។ ត្រូវរក្សាការ នៅដាច់ ឆ្ងាយពីគ្នា ដែលបានណែនាំ យ៉ាងតិចបំផុត ៦ ហ្វីត ពីអ្នកដទៃ លើកលែងតែការងារជាក់លាក់ ដែលតម្រូវ អោយមាន ចំងាយ តិចជាង ហើយត្រូវពាក់គម្របមុខ នៅពេលធ្វើការជិត ឬជាមួយអ្នកដទៃ។
  - សំឡាប់មេរោគចំពោះ ឬទៅលើវត្ថុ និងផ្ទៃដែលបានប៉ះពាល់ជាញឹកញាប់ ដូចជាស្ថានីយការងារ, ក្តារចុច, ទូរស័ព្ទ, ដៃរទេះរុញ, ម៉ាស៊ីនផ្សេងៗ, ឧបករណ៍ចែករំលែកទាំងឡាយ និងប្រដាប់មូលកាន់តាមមាត់ទ្វារ។ នេះគួរតែត្រូវ បានធ្វើរៀងរាល់ម៉ោង ក្នុងកំឡុងពេលម៉ោងធ្វើការ។ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានចែកចាយដល់និយោជិកទាំងអស់។
- ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានចែកចាយដល់និយោជិកទាំងអស់។

## B. ការរៀបចំទីលានវាយកូនហ្គោល

- រនាស់, ប្រដាប់លាងគ្រាប់បាល់, កៅអីអង្គុយវែង, ប្រអប់ចែក និងប្រអប់ខ្សាច់ ត្រូវបានយកចេញ ដើម្បីលុបបំបាត់នូវចំណុចនានា ដែលប៉ះរួមគ្នាទូទៅ។
- ទីលានវាយកូនហ្គោល ដាក់ពែងពណ៌បៃតងត្រូវបានតំឡើង តាមរបៀប "មិនចេះប៉ះ"។ ស្មៅ ឬសម្ភារៈផ្សេងទៀត អាចត្រូវបានប

ញ្ចូល។ គ្មានពេលណាទាំងអស់ ដែលបាល់ទាំងមូលនៅហ្នឹង ឬសម្រាកនៅពីក្រោមផ្ទៃដាក់។

- ☐ ត្រូវយកចេញ ឬគ្របនូវក្បាលរូបីណេទឹកផឹក និងម៉ាស៊ីនធ្វើអោយទឹកត្រជាក់។

## C. កន្លែងអនុវត្ត

- ☐ មិនអនុញ្ញាតអោយមានការជួបជុំគ្នា នៅកន្លែង ឬជួរវាយយកចំងាយឡើយ។ ប្រសិនបើចាំបាច់ ត្រូវអនុវត្តនូវការកំណត់រយៈពេលអតិបរមាចំនួន ១ ម៉ោង សម្រាប់ការប្រើប្រាស់ នូវជួរវាយយកចំងាយ។
- ☐ គ្មានកីឡាកររវាយកូនគោលណាម្នាក់ អនុញ្ញាតិអោយឈរនៅពីក្រោយស្ថានីយ៍វាយ ក្នុងខណៈពេលរង់ចាំកីឡាកររវាយកូនគោលម្នាក់ទៀត បញ្ចប់នោះឡើយ។ ទីវាយយកចំងាយជួរកណ្តាល អាចមានចម្ងាយ ៨ ហ្វីតពីគ្នា ដំរាបណាតំបន់សម្រាប់កីឡាករ/អ្នកលេងខាងឆ្វេងដៃ ត្រូវបានដាក់ជាក្រុមជាមួយគ្នា ហើយបំបែកចេញ ពីអ្នកកីឡាករ/អ្នកលេងខាងស្តាំដៃយ៉ាងតិច ១២ ហ្វីត។ ការបញ្ជាក់បន្ថែមទាក់ទងនឹងសំណាងរបស់កម្មករ បានត្រូវផ្តល់ជូន។ កន្លែង ឬទីវាយយកចំងាយដែលមានរបាំងថេរ ប្រើតែសំរាប់រៀងរាល់ពីរតូបប៉ុណ្ណោះ។
- ☐ កន្ត្រកជួរ ឬវាយយកចម្ងាយ ត្រូវបានធ្វើអនាម័យអោយបានទៀងទាត់។
- ☐ គ្រាប់បាល់ជួរ ត្រូវបានលាង បន្ទាប់ពីការប្រើប្រាស់រួចម្តងៗ។
- ☐ ម៉ាស៊ីនចែកចាយបាល់ ត្រូវបានធ្វើអនាម័យជាញឹកញាប់។

## D. ពិធីការក្នុងការថែទាំបុគ្គលិក

- ☐ បង្កើតឡើងនូវពេលវេលាចាប់ផ្តើមធ្វើការ និងការផ្លាស់ប្តូរវេនបន្តរបន្ទាប់គ្នា សម្រាប់បុគ្គលិក ដើម្បីកំណត់ចំនួនបុគ្គលិកនៅនឹងកន្លែង, នៅការប្រជុំក្រុម, នៅឯពេលសំរាកអាហារថ្ងៃត្រង់ និងកំឡុងពេលចេញដំណើរពីធ្វើការ។ គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតិអោយប្រមូលផ្តុំជាក្រុមឡើយ។
- ☐ ការប្រជុំបុគ្គលិក ត្រូវបានធ្វើឡើងនៅទីវាលបើកចំហរ ដូចជា នៅចំណតរថយន្ត ឬកន្លែងស្តុកឥវ៉ាន់  ធំៗ ដើម្បីរក្សានូវគំលាតឆ្ងាយរាងកាយពីគ្នា។
- ☐ ការប្រើប្រាស់នាឡិកាពេលវេលាគួរត្រូវបានបញ្ឈប់ ប្រសិនបើអាចធ្វើទៅបាន។
- ☐ មិនអនុញ្ញាតអោយភ្ញៀវ ឬអ្នកតំណាងលក់ នៅលើ ឬនៅក្នុងកន្លែងថែទាំ ទីលានវាយកូនហ្គោល  ឡើយ។ នេះរួមបញ្ចូលទាំង អ្នកចែកចាយខាងក្រៅ និងអ្នកតំណាងក្រុមហ៊ុនផលិតទាំងឡាយ។ ការប្រជុំ ត្រូវបានធ្វើឡើងតាមទូរស័ព្ទ, ហ្សូម (zoom) ឬវេទិកានិម្មិតផ្សេងៗ។

LONGBEACH HEALTH & HUMAN SERVICES

- និយោជិកទាំងអស់ត្រូវបានតំរូវអោយលាងដៃបាន ២០ វិនាទី មុនពេលចាប់ផ្តើមវេនរបស់ពួកគេ, មុន និងក្រោយពេលសម្រាកអាហារថ្ងៃត្រង់, បន្ទាប់ពីប្រើបន្ទប់ទឹក និងមុនពេលចេញដំណើរពីធ្វើការ នៅថ្ងៃនោះ។ ការលាងដៃញឹកញាប់ច្រើន ត្រូវបានណែនាំ តាមដែលអាចធ្វើទៅបាន។ បន្ទប់ឡក់កើ ឬកន្លែងទូរចាក់សោរដាក់ឥវ៉ាន់ ត្រូវបានសម្អាតអោយអស់នូវរបស់របរផ្ទាល់ខ្លួន។ ឯកសណ្ឋានបន្ថែម, ប្រដាប់ប្រដារ និងរបស់របរផ្ទាល់ខ្លួនទាំងអស់ អាចត្រូវបានរក្សាទុកនៅក្នុងយានយន្តផ្ទាល់ខ្លួន នៅនឹងកន្លែង។ មិនមានការអនុញ្ញាតិអោយរក្សាទុក នូវរបស់របរផ្ទាល់ខ្លួន នៅនឹងកន្លែងឡើយ។
- ការប្រើប្រាស់ របស់របរប្រើប្រាស់ទូទៅនៅបន្ទប់សំរាក (ឧទាហរណ៍ ប៉ាន់កាហ្វេ, ម៉ាស៊ីនលក់, ទូរទឹកកក និងមៃក្រូវ៉េវ) ត្រូវបានផ្អាក។ ម៉ាស៊ីនធ្វើអោយត្រជាក់ផ្ទាល់ខ្លួន ត្រូវបានណែនាំសម្រាប់ពេលញុំាអាហារ/ភេសជ្ជៈផ្ទាល់ខ្លួន ហើយគួរតែទុកនៅក្នុងយានយន្តផ្ទាល់ខ្លួន។
- កន្លែងសសំរាក និងអាហារថ្ងៃត្រង់ទីពីរ ត្រូវបានបង្កើតឡើង ប្រសិនបើអាចធ្វើទៅបាន ដើម្បីអនុញ្ញាតិអោយមានការឃ្លាតឆ្ងាយរាងកាយពីគ្នា បានកាន់តែទូលាយជាងមុន។
- មិនមាននិយោជិកណា ក្រៅពីយន្តការី ឬមេកានិចទីលានវាយកូនហ្គោល ត្រូវបានអនុញ្ញាតិអោយនៅក្នុងតំបន់មេកានិចឡើយ។ មេកានិច ត្រូវបានណែនាំអោយអនុវត្តនូវការប្រុងប្រយ័ត្នចាំបាច់ទាំងអស់ ដើម្បីធានាថា រាល់ឧបករណ៍ និងចំណុចដែលមានការប៉ះពាល់សំខាន់ៗនានា ត្រូវបានសម្អាត និងជូតជម្រះយ៉ាងទៀងទាត់ (ឧទាហរណ៍ ម៉ាស៊ីនកិន, កៅអីធ្វើការវែង និងឧបករណ៍ប្រើប្រាស់ទូទៅ)។ មេកានិចទាំងអស់ ត្រូវបានលើកទឹកចិត្តអោយប្រើដៃដែលមានអនាម័យជានិច្ច និងពាក់ស្រោមដៃជំរការពារ ក្នុងកំឡុងម៉ោងធ្វើការ។
- គណៈគ្រប់គ្រងនឹងកំណត់នូវគោលការណ៍ណែនាំនានា សម្រាប់ការសម្អាតកន្លែង យ៉ាងហោចណាស់បីដងក្នុងមួយថ្ងៃ; (ពេលព្រឹក បន្ទាប់ពីការមកដល់របស់បុគ្គលិក, និងក្រុមចាកចេញទៅទីលានវាយកូនហ្គោល, បន្ទាប់ពីម៉ោងអាហារថ្ងៃត្រង់, និងនៅចុងបញ្ចប់នៃវេនការងារ នៅពេលដែលបុគ្គលិកគ្រប់រូប បានចាកចេញពីការងារនៃថ្ងៃនោះ ហើយផ្តោតលើចំណុចដែលបានប៉ះពាល់ទាំងអស់ (កន្លែងមូលកាន់តាមមាត់ទ្វារ, បន្ទប់ទឹក, តុ, កៅអី, ស្នូកផ្ទុកទឹក, កុំព្យូទ័រ/ក្តារចុច ។ល។) កន្លែងដែលប៉ះពាល់ច្រើន អាចត្រូវការនូវការសំអាតអោយបានញឹកញាប់។

## E. បរិយាកាសការងារក្នុងកំឡុងវគ្គសិក្សា

- រក្សានូវគំលាតឆ្ងាយពីគ្នា យ៉ាងតិច ៦ ហ្វីត នៅគ្រប់ពេលទាំងអស់។
- ស្រោមដៃការពារដែលអាចដោះចេញបាន ត្រូវពាក់ និងប្តូរចេញ នៅពេលចាំបាច់ដោយបុគ្គលិក។ តំរូវ និងអនុញ្ញាតិអោយបុគ្គលិកមានពេលវេលាគ្រប់គ្រាន់ ដើម្បីលាងសំអាត ឬធ្វើអនាម័យដៃរបស់ពួកគេ រៀងរាល់ ៣០ នាទីម្តង ឬទៅតាមតម្រូវការ ប្រសិនបើមានការផ្តល់អោយនូវស្រោមដៃ។
- ឧបករណ៍ ដូចជារទេះ និងវិទ្យុ ត្រូវបានប្រគល់អោយបុគ្គលិក។ មានការដាក់ចេញនូវពិធីការសំរាប់សំអាត នូវរាល់ចំណុច

ដែលមានការប៉ះពាល់ លើឧបករណ៍ទាំងអស់។ បុគ្គលិកនឹងទទួលខុសត្រូវចំពោះការសំឡាប់មេរោគ នូវឧបករណ៍នានា មុនពេលប្រើប្រាស់ និងទៀងទាត់ ក្នុងកំឡុងពេលប្រតិបត្តិការ។ មានវត្ថុសំឡាប់មេរោគ នៅតាមស្ថានីយ៍ឧបករណ៍សំខាន់ៗ សម្រាប់អោយបុគ្គលិកជូតជំរះ ឬសំអាត នូវឧបករណ៍នានា មុន និងក្រោយពេលប្រើប្រាស់ (ឧទាហរណ៍ ប៉ៃល, រនាស់, កំប៉ុងប្រេង, ប្រដាប់កាត់ពែង ។ល។)។

- អ្នកធ្វើការ នឹងត្រូវបំបែកជាហ្វូងដែលមានសមាជិកប្រាំបួននាក់នៅខាងមុខ និងសមាជិកប្រាំបួននាក់នៅខាងក្រោយ ហើយនៅតែបន្តស្ថិតនៅក្នុងហ្វូងសមាជិកក្រុមនេះដដែលៗ តាមដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយនូវអន្តរកម្មនៃអ្នកធ្វើការ ឬក្រុមទាំងមូល។
- ការបណ្តុះបណ្តាលផ្នែកផ្សេងៗនៃគ្រឿងបរិក្ខារ ត្រូវបានធ្វើឡើងខណៈពេលដែល រក្សាអោយបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា។ នៅពេលដែលអាចធ្វើទៅបាន, ការបណ្តុះបណ្តាលឧបករណ៍នឹងត្រូវបានប្រតិបត្តិដោយការឆ្លុះបញ្ចាំង, ដែលគ្រូ និងអ្នកបណ្តុះបណ្តាលម្នាក់ៗ ធ្វើការជាមួយនឹងផ្នែកនានា នៃឧបករណ៍ដែលចំណាំបាន ដដែលៗរបស់ពួកគេ ដើម្បីលុបបំបាត់នូវតម្រូវការនៃការចែករំលែកឧបករណ៍ នៅចំងាយជិតៗគ្នា។

## F. ការប្រកួត និងការលេងជាក្រុម

- ត្រូវកំណត់ពេលវេលាកក់ទុកជាមុន មិនអោយមានអ្នកលេង លើសពី ៤ នាក់ ដែលមិនចាំបាច់មកពីគ្រួសារតែមួយ ឬយូនីតរស់នៅតែមួយនោះឡើយ)។ ក្រុមនីមួយៗត្រូវតែមានស្ថេរភាព (ឧទាហរណ៍ មនុស្សនោះមិនអាចជំនួស ឬចេញពីក្រុមបានទេ)។
- ការប្រកួតសម្រាប់កីឡាមនុស្សពេញវ័យ និងយុវជន ត្រូវតែគោរពតាមពិធីសាររបស់រដ្ឋសម្រាប់និងតម្រូវការ ដែលអាចអនុវត្តបាន នៅក្នុងពិធីសារនេះ។ កីឡាយុវជន និងការកំសាន្តសំរាប់មនុស្សពេញវ័យនិងតម្រូវការផ្សេងៗ ដែលមាននៅក្នុងពិធីសារនេះ។
- អាចនឹងរៀបចំអោយមានការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង មិនអោយលើសពី ៤ នាក់ ក្នុងមួយប្រកួត ប្រសិនបើការលេងបែបនេះនឹងមិនបង្កើនវត្តមាននៃចំនួនមនុស្ស នៅកន្លែងលេងនោះ ក្នុងពេលតែមួយ។ ត្រូវរៀបចំកាលវិភាគទុកជាមុន ចំពោះការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង ដើម្បីឱ្យទុកអោយមានចន្លោះពេលឃ្លាតគ្នា ពីហ្គេមនីមួយៗមិនតិចជាង ១០ នាទី។ ត្រូវលើកទឹកចិត្តអោយបង់ប្រាក់ជាមុន និងការចុះឈ្មោះតាមអេឡិចត្រូនិក សម្រាប់ការលេងជាក្រុម ឬការលេងដែលបានបង្កើតឡើង។ មានការលើកទឹកចិត្តជាខ្លាំង អោយប្រើនូវប័ណ្ណពិន្ទុអេឡិចត្រូនិក, ព័ត៌មាន និងសន្លឹកច្បាប់។ បើកន្លែងណាដែលប្រើប័ណ្ណពិន្ទុក្រដាសវិញនោះ,សមាជិកម្នាក់ក្នុងក្រុម គួរតែរក្សាពិន្ទុអោយកីឡាករទាំងអស់ ដើម្បីជៀសវាងការប៉ះពាល់ដែលមិនចាំបាច់ រវាងកីឡាករទាំងឡាយ។ ការដាក់បង្ហាញអ្នកលក់នៅនឹងកន្លែង ត្រូវតែគោរពតាមពិធីសារលក់រាយដោយផ្ទាល់ និងត្រូវមានចម្ងាយយ៉ាងតិច ៦ ហ្វីត រវាងការដាក់បង្ហាញនានារបស់អ្នកលក់។
- ត្រូវហាមឃាត់នូវការប្រកួត ឬព្រឹត្តិការណ៍ដែលមានការចូលរួមច្រើនជាងពីរក្រុម។ "ក្រុម" ត្រូវបានកំណត់ជាក្រុមកីឡាករដែលបង្កើតជាក្រុមមួយ នៅផ្នែកម្ខាងទៀត នៅក្នុងការប្រកួតកីឡា។ "ក្រុម" មិនរាប់បញ្ចូលនូវក្រុម ឬកំរឹតច្រើន ដែលមកពីលីក ឬក្រុមដែលមានបទពិសោធន៍រួមតែមួយ (ឧទាហរណ៍ ក្រុមថ្មីថ្មោង, ក្រុមមិនសូវមានបទពិសោធន៍ប្រកួត និងក្រុមមានបទពិសោធន៍

ខ្ពស់នានា និងពីសាលា ឬលីកតែមួយ ត្រូវបានគេចាត់ទុកថា ជាក្រុមផ្សេងគ្នា)។

- ក្នុងមួយថ្ងៃ ដែលអាចត្រូវលេងបានច្រើនបំផុត គឺប្រកួតបានតែម្តងប៉ុណ្ណោះ, ក្នុងមួយក្រុម (ឬចំពោះបុគ្គលម្នាក់ ប្រកួតបានតែមួយហ្គេមតែប៉ុណ្ណោះ) (ឧទាហរណ៍ គ្មានការប្រកួតវិលជុំ ឬការប្រកួតច្រើនក្នុងថ្ងៃតែមួយជាដាច់ខាត)។

## G. នីតិវិធីចុងបញ្ចប់នៃវេន

- បុគ្គលិកមានការទទួលខុសត្រូវក្នុងការសំឡាប់មេរោគ ចំពោះឧបករណ៍ប្រើប្រាស់ បន្ទាប់ពីប្រតិបត្តិការរួច។ មានវត្ថុ សំឡាប់មេរោគ នៅតាមស្ថានីយ៍ឧបករណ៍សំខាន់ៗ សម្រាប់អោយបុគ្គលិកជូតជំរះ ឬសំអាតនូវឧបករណ៍នានា មុននិងក្រោយពេលប្រើប្រាស់ (ឧទាហរណ៍ ប៉ែល, រនាស់, កំប៉ុងប្រេង, ប្រដាប់កាត់ពែង ។ល។)។
- តំរូវអោយបុគ្គលិកទាំងអស់ ត្រូវចាកចេញពីទ្រព្យសម្បត្តិភ្លាមៗ បន្ទាប់ពីចប់វេនការងារ របស់ពួកគេ។
- សមាជិកក្រុមនីមួយៗត្រូវបានរំលឹក អំពីសារៈសំខាន់នៃការឃ្លាតឆ្ងាយរាងកាយពីគ្នា ពេលចេញពីការងារ ក៏ដូចជា ក្នុង កំឡុងពេលបំពេញការងារ។

## H. ពិធីការត្រួតពិនិត្យ

- ប្រតិបត្តិករទីលានវាយកូនហ្គោលមាន 'ឯកអគ្គរដ្ឋទូតសុវត្ថិភាព' ម្នាក់ នៅនឹងកន្លែងក្នុងអំឡុងរាល់ពេលម៉ោងធ្វើការទាំងអស់។ គោលបំណងតែមួយគត់ នៃបុគ្គលិកដែលត្រូវបានគេនិយាយនោះ គឺដើម្បីធានាថា បុគ្គលិកទីលានវាយកូនហ្គោល និងភ្ញៀវទាំងឡាយ អនុវត្តតាមនូវរាល់តម្រូវការនានា នៃពិធីការសុវត្ថិភាពនៅឃ្លាតឆ្ងាយពីគ្នា។ឯកអគ្គរដ្ឋទូតសុវត្ថិភាពពាក់ស្លាកឈ្មោះ ហើយរទេះវាយកូនហ្គោលដែលត្រូវប្រើ ត្រូវបានធ្វើសញ្ញាសំគាល់យ៉ាងច្បាស់ជាមួយនិងសញ្ញា ថា "ឯកអគ្គរដ្ឋទូតសុវត្ថិភាព"។ ម៉ូនីទ័រសុវត្ថិភាព តែងតែមានឯកសារនេះ ជាប់ជាមួយនឹងពួកគេ ដើម្បីយោងអំពីពិធីការសុវត្ថិភាពនានា ដែលមានតំរូវការ។
- ការរួសរាយរាក់ទាក់, ប៉ុន្តែការប្រាស្រ័យទាក់ទងយ៉ាងម៉ឺងម៉ាត់ ជាមួយនឹងភ្ញៀវណាដែលរំលោភបំពានលើតំរូវការនៃ ពិធីការសុវត្ថិភាព គឺជាកត្តាចាំបាច់។ ភ្ញៀវទាំងឡាយ ត្រូវបានក្រើនរំលឹកថា រាល់ការបំពារបំពានណាមួយ នៃពិធីការសុវត្ថិភាពនៅឃ្លាតឆ្ងាយពីគ្នា នឹងបង្ករនូវភាពអន្តរាយដល់ការបន្តរនូវប្រតិបត្តិការ នៃទីលានវាយកូនហ្គោលនានា ក្នុងស្រុក។
- ភ្ញៀវណាម្នាក់, ដែលបដិសេធមិនគោរពតាមពិធីការសុវត្ថិភាពនានា បន្ទាប់ពីផ្តល់នូវការព្រមានម្តងរួចហើយនោះ ត្រូវបានស្នើសុំអោយចាកចេញ ពីទ្រព្យសម្បត្តិភ្លាម។

**ដើម្បីរាយការណ៍ការបំពាន**

**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**

**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

## វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបានដាក់វាយ
## នៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ

អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:

ឈ្មោះទំនាក់ទំនងទីលានវាយកូនហ្គោល: ______________________ លេខទូរស័ព្ទ: ______________________

កាលបរិច្ឆេទកែប្រែចុងក្រោយ: ______________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**